USAID
FROM THE AMERICAN PEOPLE

WINROCK INTERNATIONAL
Putting Ideas to Work



**គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (CTIP)**

**ចេញផ្សាយលេខ៦ ខែមករា - មីនា ឆ្នាំ២០១៥**

## បណ្តាញអ្នករត់ម៉ូតូឌុប ដែលទទួលការបណ្តុះបណ្តាល ពីគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានជួយដល់ជនរងគ្រោះដ៏ទៃទៀត

ត.ស ជាស្ត្រីវ័យ៣៩ឆ្នាំ រស់នៅខេត្តកោះកុង ដែលមានព្រំប្រទល់ជាប់នឹងភាគខាងត្បូងប្រទេសថៃ ហើយគាត់មានបំណងធ្វើចំណាកស្រុកដើម្បីរកប្រាក់ឈ្នួលសមរម្យមួយ។ គាត់បានសម្រេចចិត្តទៅប្រទេសថៃ ដោយទាក់ទងមេខ្យល់ ដែលបានប្រាប់គាត់ និងអ្នកចំណាកស្រុកដទៃទៀតថាពួកគាត់នឹងធ្វើការជាអ្នកសម្អាត និងទទួលបានប្រាក់៣៥០បាត ក្នុងមួយថ្ងៃ (ប្រហែលជា ១០ដុល្លារ)។

ខុសពីការស្មាន មេខ្យល់បានយកប្រាក់របស់គាត់ និងបង្ខំឲ្យគាត់ធ្វើការក្នុងរោងចក្រផលិតដែកមួយកន្លែងដែលគាត់ធ្វើការធ្ងន់ទាំងយប់ទាំងថ្ងៃ ហើយមិនទទួលបានប្រាក់ខែទេ បន្ទាប់ពីគាត់ធ្វើការបានមួយខែរួចមក។ ម្ហូបអាហារមានការខ្វះខាត។ នៅពេលដែលគាត់ សុំឲ្យមេខ្យល់ជួយប្តូរការងារឲ្យគាត់ មេខ្យល់បែរជាបញ្ជូនគាត់ឲ្យទៅធ្វើការងារស្រដៀងគ្នានេះទៅវិញ។

បន្ទាប់ពីយល់ច្បាស់ពីការសន្យាក្លែងក្លាយរបស់មេខ្យល់ គាត់បានលួចរត់ហើយត្រលប់មកប្រទេសកម្ពុជាវិញ។ នៅព្រំប្រទល់ខេត្តកោះកុង សមាជិកនៃបណ្តាញអ្នករត់ម៉ូតូឌុប ដែលទទួលការបណ្តុះបណ្តាលពីគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានជួបគាត់ ហើយបញ្ជូនគាត់ឲ្យទៅមជ្ឈមណ្ឌលថៃទាំសុខភាពកុមារ (HCC) ដែលជាដៃគូរបស់គម្រោង ដើម្បីរកជំនួយ។

មជ្ឈមណ្ឌលថៃទាំសុខភាពកុមារ បានបង្កើតបណ្តាញអ្នករត់ម៉ូតូឌុបតាមតំបន់ព្រំដែន ដែលពួកគាត់បានទទួលការបណ្តុះបណ្តាលជាទៀងទាត់អំពីការកំណត់អត្តសញ្ញាណរបស់ជនរងគ្រោះ និងរបៀបសហការជាមួយអង្គការក្រៅរដ្ឋាភិបាលក្នុងការបញ្ជូនជនរងគ្រោះ ដើម្បីរកជំនួយ។ អ្នករត់ម៉ូតូឌុបទាំងនោះក៏អាចចែករំលែកព័ត៌មាន ទៅដល់ពលករចំណាកស្រុក និងសមាជិកសហគមន៍អំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងសេវាកម្ម ដែលពលករចំណាកស្រុកអាចស្វែងរកបានដើម្បីពួកគេទទួលបានការការពារ និងទាមទារ សិទ្ធិ និងយុត្តិធម៌របស់ពួកគេ។

**«អគុណដល់ការគាំទ្រពីគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលទទួលជំនួយពីទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍអន្តរជាតិ ឥឡូវខ្ញុំមានគម្រោងសម្រាប់អនាគតល្អប្រសើរជាងមុន» ត.ស និយាយ។**

ត.ស បានស្នាក់នៅក្នុងមជ្ឈមណ្ឌលថៃទាំសុខភាពកុមាររយៈពេលពីរយប់ ដើម្បីសម្រាកយកកម្លាំងមុននឹងត្រលប់ទៅសហគមន៍របស់គាត់វិញ។ មជ្ឈមណ្ឌលថៃទាំសុខភាពកុមារបានផ្តល់ជំនួយផ្នែកវេជ្ជសាស្ត្រផ្តល់ការប្រឹក្សាផ្លូវចិត្ត និងផ្តល់ការធ្វើដំណើរត្រលប់ទៅសហគមន៍របស់គាត់។ គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក៏បានចុះទៅធ្វើបទសម្ភាសន៍ជាមួយនឹងគាត់ ដើម្បីដឹងពីតម្រូវការរបស់គាត់ និងបានបណ្តុះបណ្តាលគាត់ពីរបៀបចិញ្ចឹមមាន់ និងទាផងដែរ។ បន្ទាប់ពីត្រលប់ទៅដល់សហគមន៍វិញ ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិបានផ្តល់ជំនួយថវិការដល់គាត់ដើម្បីទិញទា ១៦ ក្បាល មាន់ ១៦ ក្បាល និងឧបករណ៍សម្រាប់កិនទឹកអំពៅ។ បច្ចុប្បន្ននេះ គាត់កំពុងតែពង្រីកអាជីវកម្មរបស់ខ្លួន ហើយសត្វចិញ្ចឹមទាំងនោះក៏កំពុងតែធំលូតលាស់យ៉ាងឆាប់រហ័សផងដែរ។



## សង្ខេបទិន្នន័យខ្លះរបស់គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស CTIP (2011-2015)

* ចំនួនអ្នករស់រាននៃអំពើជួញដូរ ក្រោមការគាំទ្ររបស់គម្រោង
- ៧២៦ នាក់រួចផុតពីការជួញដូរពលកម្ម
- ៨០ នាក់រួចផុតពីការជួញដូរផ្លូវភេទ
- ១៤១ នាក់រួចផុតពីការកេងប្រវ័ញ្ចពលកម្ម

* ជំនួយ និងសេវាកម្មដែលបានផ្តល់ឲ្យអ្នកដែលរួចផុតពីគ្រោះថ្នាក់
- ៥១៤ នាក់បានធ្វើមាតុភូមិនិវត្តន៍
- ៦១៨ នាក់បានទទួលការប្រឹក្សាផ្លូវចិត្ត
- ៤២៩ នាក់បានទទួលការប្រឹក្សាផ្នែកច្បាប់
- ៩១ នាក់បានទទួលជំនួយក្នុងការប្តឹងប្រឆាំងនឹងអ្នកប្រព្រឹត្តបទឧក្រិដ្ឋ
- ៥១ នាក់បានទទួលការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងរបរចិញ្ចឹមជីវិត
- ២១៥ នាក់បានធ្វើសមាហរណកម្ម
- ១១៤ នាក់បានទទួលទុនបង្កើតមុខរបរ និងប្រាក់ជំនួយចាប់ផ្តើមជីវិតឡើងវិញ

* តួលេខបានធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤

## ពាក់មី ប្រើប្រាស់ទេពកោសល្យសិល្បៈរបស់ខ្លួនរួមចំណែកប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស

អំឡុងពេលប្រារព្ធទិវាប្រឆាំងអំពើជួញដូរមនុស្សនៅថ្ងៃទី១២ ខែធ្នូ ក្នុងខេត្តសៀមរាប គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានអញ្ជើញក្រុមកំប្លែងល្បីប្រចាំស្ថានីយន៍ទូរទស្សន៍ CTN គឺក្រុមពាក់មីមកសម្តែងជាពិសេសស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ ក្រុមកំប្លែងបានប្រាប់ទៅដល់ទស្សនិកជនដែលកំពុងតែរីករាយអំពីហានិភ័យនៃការធ្វើចំណាកស្រុកខុសច្បាប់ និងនិតិវិធីក្នុងការធ្វើចំណាកស្រុកដោយស្របច្បាប់ទៅកាន់ប្រទេសថៃ និងបានពន្យល់ពីរបៀបទទួលយកការសម្រេចចិត្តអំពីការធ្វើចំណាកស្រុក។



## ប៉ូលីសឃុំ ដែលទទួលការបណ្តុះបណ្តាលពីគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានសហការជាមួយនឹងប៉ូលីសប្រឆាំងអំពើជួញដូរមនុស្សក្នុងការចុះបង្ក្រាបហាងម៉ាស្សា

ផ្នែកមួយនៃយុទ្ធសាស្រ្តរបស់គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដើម្បីចោទទោសលើករណីអំពើជួញដូរមនុស្សគឺការបណ្តុះបណ្តាលក្រុមប៉ូលីសឃុំឲ្យយល់ដឹងពីបញ្ហាអំពើជួញដូរ និងលើកទឹកចិត្តពួកគាត់ឲ្យរាយការណ៍ករណីដែលកើតមាន។ កាលពីខែ កក្កដា មន្រ្តីប៉ូលីសមកពីឃុំស្ទឹងវែង ខេត្តកោះកុង ដែលបានទទួលការបណ្តុះបណ្តាលពីគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានរាយការណ៍ពីហាងម៉ាស្សាមួយកន្លែងដែលគាត់សង្ស័យថាមានការសម្របសម្រួលផ្តល់សេវាកម្មផ្លូវភេទ។ អគុណដល់ការរាយការណ៍របស់គាត់ ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនិតិជន (OAHT&JP) បានធ្វើការស៊ើបអង្កេតបឋមមួយ ដែលបង្ហាញថា ហាងម៉ាស្សានោះពិតជាបានប្រព្រឹត្តបទល្មើសនោះមែន។

ជាលទ្ធផល ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនិតិជនបានសហការជាមួយនឹងប៉ូលីសឃុំស្ទឹងវែងចុះបង្ក្រាបហាងម៉ាស្សា។ អំឡុងពេលចុះឆែកឆេរ ប៉ូលីសបានរកឃើញភស្តុតាង ដែលហាងម៉ាស្សាពិតជាបានផ្តល់សេវាផ្លូវភេទដល់អតិថិជន ដែលរួមមានសៀវភៅកត់ត្រាពីចំណាយ និងចំណូលរបស់ស្រ្តីរកស៊ីផ្លូវភេទ៤នាក់។ ស្រ្តីទាំងនេះ ដែលត្រូវបានគេកំណត់អត្តសញ្ញាណថា ជាជនរងគ្រោះពីអំពើជួញដូរមនុស្សបានពន្យល់ទៅកាន់ប៉ូលីសថា ម្ចាស់ហាងម៉ាស្សាយកប្រាក់ ៥០%នៃប្រាក់ដែលពួកគេទទួលបានពីការបម្រើផ្លូវភេទ។ ជនសង្ស័យពីរនាក់បានទទួលស្គាល់ការពិត និងសារភាពថាបានបើកហាងខារ៉ាអូខេមួយ។ ឥឡូវនេះពួកគេត្រូវបានចោទប្រកាន់ពីបទសញ្ជារកម្ម ក្រោមមាត្រាទី២៨៨ នៃក្រមព្រហ្មទណ្ឌ និងស្ថិតក្រោមការឃុំខ្លួនត្រៀមជំនុំជម្រះក្តី។

ប្រធានរដ្ឋបាលប៉ូលីស អធិការស្រុក និងប្រធានការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនិតិជន បានសម្តែងភាពរីករាយក្នុងកិច្ចសហប្រតិបត្តិការយ៉ាងល្អក្នុងអំឡុងពេលចុះធ្វើការលើករណីនេះ។ មន្រ្តីប៉ូលីសដែលទទួលការបណ្តុះបណ្តាលពីគម្រោងប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្សក៏បានបញ្ជាក់ផងដែរថា មន្រ្តីថ្នាក់ក្រោម និង ប្រធានរដ្ឋបាលប៉ូលីសបានបញ្ជូនករណីនេះទៅថ្នាក់លើដើម្បីចាត់វិធានការបន្ត។ សកម្មភាពរបស់ប៉ូលីស និងកិច្ចសហប្រតិបត្តិការដ៏រឹងមាំរបស់ពួកគេបានចង្អុលបង្ហាញថាពួកគេកំពុងតែអនុវត្តនូវអ្វី ដែលពួកគេបានរៀនពីវគ្គបណ្តុះបណ្តាលរបស់គម្រោងប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស។

## សោកនាដកម្មនៃការជួញដូរមនុស្សត្រូវបានបង្ហាញក្នុងភាពយន្តថ្មីរបស់គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទើបតែធ្វើការចាក់បញ្ចាំងភាពយន្តថ្មី ដែលបរិយាយពីភាពឈឺចាប់ និងរងទុក្ខដោយសារអំពើជួញដូរមនុស្ស។ “តម្លៃកូនក្រមុំ” គឺជាដំណើររឿងរបស់ជនរងគ្រោះពីអំពើជួញដូរមនុស្ស ដែលត្រូវបានគេល្បួងឲ្យរៀបអាពាហ៍ពិពាហ៍ជាមួយនឹងបុរសអ្នកមាននៅប្រទេសចិន ហើយចុងក្រោយត្រូវធ្លាក់ខ្លួនជាទាសករ។ ដំណើររឿងរបស់នាង មិនមែនមានជាករណីដាច់ដោយឡែកពីគេនោះទេ។

ក្នុងឆ្នាំ២០១៤ ស្រ្តីប្រមាណជា៣០នាក់ បានត្រលប់មកប្រទេសកម្ពុជាវិញបន្ទាប់ពីគេចផុតពីមានការរំលោភបំពានក្រោមរូបភាពអាពាហ៍ពិពាហ៍នៅប្រទេសចិន។ គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានជួយដល់ស្រ្តី១៨នាក់ក្នុងចំណោមស្រ្តីរងគ្រោះទាំងនោះ ដោយផ្តល់សេវាកម្មជាច្រើនដូចជា៖ ធ្វើមាតុភូមិនិវត្តន៍ ផ្តល់ជំនួយផ្នែកច្បាប់ និងផ្តល់ជំនួយសមាហរណកម្ម។

ទោះបីជាយ៉ាងនេះក្តី ការជួយគាំទ្រដល់ជនរងគ្រោះ មិនមែនមានភាពងាយស្រួលរហូតនោះទេ។ កិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាលចិន និងកម្ពុជាទាមទារឲ្យមានច្រើនជាងនេះ។ មិនតែប៉ុណ្ណោះ មិនមានការធ្វើមាតុភូមិនិវត្តន៍ និងយន្តការគាំទ្រណាមួយផ្តល់ឲ្យជនរងគ្រោះនោះទេក្នុងពេលបច្ចុប្បន្ននេះ។ ជំនួយ ដែលពួកគេទទួលបានពីអគ្គកុងស៊ុលនៅមានកំណត់នៅឡើយ។ រដ្ឋាភិបាលទាំងពីរ គួរតែចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការជួញដូរមនុស្ស។ ម្យ៉ាងទៀត អង្គការក្រៅរដ្ឋាភិបាលនៃប្រទេសទាំងពីរក៏គួរតែសហការគ្នាឲ្យកាន់តែច្រើន។ ជាចុងក្រោយ ដំណើរការរឹងមាំរបស់ប្រព័ន្ធតុលាការក៏ត្រូវការជាចាំបាច់ ដើម្បីថ្កោលទោសជនប្រព្រឹត្តបទល្មើស។

លោកអ្នកអាចចូលទស្សនាវីដេអូនេះលើគេហទំព័រ https://www.youtube.com/watch?v=PNfqa08vYFo. ឬក៏ទាញយកវីដេអូដោយផ្ទាល់ពីគេហទំព័រហ្វេសប៊ុករបស់គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស www.facebook.com/CTIP2 ។




## យុវនារី ដែលជាសសររឹងមាំវ័យក្មេង បានទទួលការឲ្យតម្លៃពីមិត្តភក្តិរបស់នាង

ជួន ផាណា ទើបតែមានអាយុ ១៨ឆ្នាំប៉ុណ្ណោះ តែនាងមានភាពចាស់ទុំជាងអាយុរបស់នាងទៅទៀត។ ផាណា គឺជាសមាជិកម្នាក់នៃបណ្តាញយុវជនស្ម័គ្រចិត្តសហគមន៍ (CYN) ក្នុងខេត្តសៀមរាប ដែលបានទទួលការបណ្តុះបណ្តាលពីសមាគមយុវជនខ្មែរ (KYA) ដែលជាដៃគូរបស់គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីផ្សព្វផ្សាយអំពីចំណាកស្រុកសុវត្ថិភាព និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងប្រទេស។ នាងធ្វើការងារស្ម័គ្រចិត្តចេញពីក្នុងបេះដូងរបស់នាង!

អ្វីដែលនាងបានធ្វើគឺការរៀបចំកិច្ចពិភាក្សាតូចមួយក្នុងសហគមន៍ និងការចូលរួមរបស់នាងក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ។ បន្ថែមលើនេះ សមាជិកនៃបណ្តាញយុវជនស្ម័គ្រចិត្តសហគមន៍ចូលរួមក្នុងកិច្ចប្រជុំទាំងនេះ ដើម្បីគាំទ្រក្នុងការដាក់បញ្ចូលអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុក ដោយសុវត្ថិភាពទៅក្នុងរបៀបវីរៈរបស់ឃុំ។ ពីដំបូងឡើយ កិច្ចការងារនេះតែងតែមិនមានភាពងាយស្រួលនោះទេ ដោយសារតែយុវជនទាំងនោះមិនត្រូវបានគេឲ្យតម្លៃក៏ព្រោះតែភាពវ័យក្មេងរបស់ពួកគេ។ សមាគមយុវជនខ្មែរបានជួយ



ពួកគេឲ្យឆ្លងកាត់ឧបសគ្គនេះ ដោយជួយពួកគេឲ្យអភិវឌ្ឍន៍លើជំនាញក្នុងការនិយាយជាសាធារណៈ និងរបៀបក្នុងការ រៀបចំនិង ដឹកនាំកម្មវិធីដែលបង្កើតឡើងអំឡុងពេលវគ្គបណ្តុះបណ្តាលរបស់USAID។ ក្នុងពេលបច្ចុប្បន្ននេះ ផាណា សហការយ៉ាងល្អជាមួយនឹង អាជ្ញាធរខេត្ត ដែលចាត់ទុកនាងជាតួអង្គសំខាន់ក្នុងសង្គម និងសម្រាប់មូលហេតុល្អផ្សេងទៀត។

ផាណា បានជួយផ្តល់នូវការណែនាំដល់អ្នកភូមិរបស់នាងទៅលើបញ្ហាចំណាកស្រុក។ តើអ្នកមានចម្ងល់អ្វីដែរឬទេ? អ្នកអាចសួរសំនួរទៅកាន់ផាណាបាន។ ថ្ងៃមួយ មានក្មេងស្រីមិនទាន់គ្រប់អាយុម្នាក់បានបង្ហាញគំនិតរបស់នាង ក្នុងការធ្វើចំណាកស្រុកទៅក្រៅប្រទេស ដោយប្រើប្រាស់អត្តសញ្ញាណប័ណ្ណរបស់បងស្រីនាង ដែលគ្រប់អាយុហើយ។ ផាណាព្យាយាមបញ្ចុះបញ្ចូលឃាត់នាង ដោយប្រាប់ពីគ្រោះថ្នាក់ដែលនាងអាចនឹងជួបប្រទះតាមរយៈហេតុការណ៍ពិត ដែលល្បីសុះសាយក្នុងប្រទេសកម្ពុជា។ ប្រជាជនចង់មានការងារធ្វើ ហើយពួកគេគិតថា នៅផ្ទះពួកគេមិនមានជម្រើសនោះទេ ហេតុដូច្នេះហើយ ពួកគេសម្រេចចិត្តកុហកពីអាយុខ្លួនឯងដើម្បីតម្រូវនឹងការទាមទារក្នុងការចេញទៅក្រៅប្រទេស ដែលម្នាក់ត្រូវមានអាយុ (១៨ ឬ ២១ ឆ្នាំ ទៅតាមប្រភេទការងារ)។

ទោះបីជាពន្យល់យ៉ាងណា ក្មេងស្រីម្នាក់នោះ នៅតែសម្រេចចិត្តចាកចេញពីសហគមន៍ទៅកាន់ទីក្រុងភ្នំពេញ។ មិនទទួលបានដំណឹងអ្វីបន្តិចសោះ ផាណា បានសម្រេចចិត្តប្រាប់រឿងនេះទៅកាន់ក្រុមប្រឹក្សាឃុំ និងក្រុមគ្រួសាររបស់ក្មេងស្រីនោះដែលបានបញ្ជូនករណីនេះទៅកាន់អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក។ នៅពេលដែល ពួកគេបានរកឃើញក្មេងស្រីនោះខ្លួនរបស់នាងពោរពេញដោយស្នាមរបួស។ ដោយចាញ់បោកឈ្មួញកណ្តាល នាងត្រូវបានគេឃុំក្នុងបន្ទប់ជាមួយនឹងអ្នកចំណាកស្រុក២០នាក់ផ្សេងទៀត។ ប្រសិនបើ អ្នកណាម្នាក់ហ៊ានស្រែកឲ្យគេជួយនោះនឹងត្រូវគេវាយយ៉ាងដំណំ។

**ឥឡូវនេះ ក្រុមប្រឹក្សាឃុំ និងអាជ្ញាធរក្នុងតំបន់គិតថា៖ «នាងក្មេងក៏ពិតមែនតែនាងពិតជាមានសមត្ថភាពក្នុងការជួយសហគមន៍បាន!»**

សូមអរគុណចំពោះការជឿជាក់យ៉ាងរឹងមាំរបស់នាង និងកម្លាំងស្មារតីក្នុងការលើកពីបញ្ហាអំពើជួញដូរមនុស្សទៅកាន់អាជ្ញាធរក្នុងតំបន់ ហើយ ផាណា បានជួយឲ្យក្មេងស្រីនោះឲ្យគេចផុតពីជីវិតវេទនា។ ផាណា គឺជាប្រភពនៃកម្លាំងជម្រុញទឹកចិត្តសម្រាប់ស្ត្រីយក្មេងផ្សេងទៀត។

## ព័ត៌មានថ្មីស្តីពីនីតិវិធីក្នុងការធ្វើចំណាកស្រុកទៅប្រទេសថៃ

ការចុះបញ្ជីនៅការិយាល័យច្រកចេញចូលតែមួយនៅប្រទេសថៃបានបញ្ចប់កាលពីខែតុលា ឆ្នាំ២០១៤។ ពលករកម្ពុជាទាំងអស់ដែលពុំបានចុះបញ្ជី និងមិនមានប័ណ្ណអនុញ្ញាតការងារដែលមានសុពលភាពគួរត្រឡប់មកប្រទេសកម្ពុជាវិញ រួចទៅកាន់ការិយាល័យច្រកចេញចូលតែមួយនៅប្រទេសកម្ពុជាដើម្បីធ្វើលិខិតឆ្លងដែន និងប័ណ្ណអនុញ្ញាតការងារ។

ពលករដែលបានចុះបញ្ជីនៅការិយាល័យច្រកចេញចូលតែមួយនៃប្រទេសថៃ និងបានទទួលបណ្ណ័អនុញ្ញាតការងារបណ្តោះអាសន្ន រហូតដល់ថ្ងៃទី៣១ខែមិនា ឆ្នាំ២០១៥ នោះនឹងត្រូវឆ្លងកាត់ដំណើរការផ្ទៀងផ្ទាត់សញ្ជាតិ។ និយោជកថៃត្រូវបញ្ជូនឯកសាររបស់ពលករទាំងអស់សម្រាប់ធ្វើការផ្ទៀងផ្ទាត់សញ្ជាតិទៅការិយាល័យការងារក្នុងស្រុក។ អាជ្ញាធរថៃនឹងចេញប័ណ្ណអនុញ្ញាតការងារ និងទិដ្ឋាការ ដែលមានសុពលភាពរហូតដល់ខែមិនា ឆ្នាំ២០១៦ (តម្លៃ ១,៥០០ បាត បូកបន្ថែមតម្លៃពិនិត្យសុខភាព និងការធានារ៉ាប់រងដោយឡែកទៀត) ហើយអាជ្ញាធរកម្ពុជានៅប្រទេសថៃនឹងចេញលិខិតឆ្លងដែន (តម្លៃ ១,៤០០ បាត)។

តម្លៃសរុប (២,៩០០ បាត បូកបន្ថែមតម្លៃពិនិត្យសុខភាព និងការធានារ៉ាប់រងដោយឡែកទៀត) អាចកាត់ចេញពីប្រាក់ឈ្នួលរបស់ពលករដោយនិយោជក ដោយអាស្រ័យលើកិច្ចព្រមព្រៀងរវាង និយោជក និងពលករ។ រហូតដល់ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ២០១៤ ពលករ និងអ្នករស់នៅក្នុងបន្ទុកចំនួន ៩០,៧៩៧បានឆ្លងកាត់ដំណើរការផ្ទៀងផ្ទាត់សញ្ជាតិ។ ចំនួនពលករកម្ពុជាសរុបចំនួន ៧៣៨,៩៤៧ បានចុះបញ្ជីនៅការិយាល័យច្រកចេញចូលតែមួយនៅប្រទេសថៃ។ កាលកំណត់សម្រាប់ប័ណ្ណអនុញ្ញាតិការងារបណ្តោះអាសន្ន (ឬកាតពណ៌ស៊ីជម្ពូ) នឹងផុតកំណត់នៅថ្ងៃទី៣១ ខែវិច្ឆិកា ឆ្នាំ២០១៥ ប៉ុន្តែដោយសារចំនួនពលករដែលដាក់ពាក្យស្នើសុំច្រើននោះនឹងមានឱកាសច្រើនក្នុងការពន្យា។

## ស្វាគមន៍សមាជិកថ្មីនៃក្រុមជួយខ្លួនឯងរបស់គម្រោង ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

មជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ (CCPCR) ជាដៃគូរបស់គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានបង្កើតក្រុមជួយខ្លួនឯង (SHG) លើក



ទី៣ យ៉ាងជោគជ័យ ដោយជ្រើសរើសសមាជិក ៣០នាក់ក្នុងចំណោមក្រុមគ្រួសាររបស់ជនរងគ្រោះ និងជនងាយរងគ្រោះ ដែលគាំទ្រដោយគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅភូមិកណ្តាល ខេត្តស្វាយរៀង។ សមាជិកនៃក្រុមជួយខ្លួនឯង គឺជាឪពុកម្តាយរបស់កុមារ ដែលជាញឹកញាប់ ត្រូវបានគេបញ្ជូនឲ្យទៅប្រទេសវៀតណាមដើម្បីសុំទាន ហើយពួកគេគឺស្ថិតនៅក្នុងភាពគ្រោះថ្នាក់ក្នុងការក្លាយជាជនរងគ្រោះសារជាថ្មីពីការកេងប្រវ័ញ្ចពលកម្ម និងការជួញដូរ។

គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបណ្តុះបណ្តាលក្រុមថ្មីនេះអំពីការគ្រប់គ្រងហិរញ្ញវត្ថុ និងផែនការអាជីវកម្ម។ គម្រោងក៏បានផ្តល់មេគោ១០ក្បាល និងប្រាក់កម្ចី ១៥០ដុល្លារ ដល់សមាជិកម្នាក់ៗទៅតាមផែនការអាជីវកម្មរបស់ពួកគេ។ អ្វីៗគឺដំណើរការបានល្អសម្រាប់សមាជិកក្រុមជួយខ្លួងឯង ដែលគាំទ្រដោយគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស! មជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ (CCPCR) ក៏កំពុងតែដំណើរការក្នុងការបង្កើតធនាគារស្រូវក្នុងភូមិតែងម៉ៅ ខេត្តស្វាយរៀង។ គណៈកម្មាធិការពិសេសបានជ្រើសរើសសមាជិក ចំនួន៦០នាក់រួចជាស្រេច ហើយក៏បានបញ្ចប់ ការសាងសង់ឃ្លាំងស្តុកស្រូវកាលពីខែធ្នូផងដែរ។

**សង្ខេប**

ផែនការសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ឥឡូវនេះ បានរៀបចំរួចជាស្រេច! វាគួរតែត្រូវបានបើកដំណើការនៅក្នុងត្រីមាសនេះ។

## បទពិចារណកថារបស់គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

ស្ត្រីកម្ពុជាជាង២០នាក់ ក្នុងពេលបច្ចុប្បន្នបានវិលត្រលប់មកប្រទេសកំណើតវិញ បន្ទាប់ពីគេចផុតចេញពីការរំលោភបំពានក្នុងអាពាហ៍ពិពាហ៍នៅប្រទេសចិន។ យ៉ាងនេះក្តី នៅមានស្ត្រីជាច្រើនទៀត ប្រហែលជាកំពុងស្ថិតនៅក្នុងស្ថានភាព ដែលជាប់ឃុំដូចជាទាសករ។

ស្ត្រីទាំងនេះបានចាកចេញពីប្រទេសកម្ពុជា ដោយចាញ់ការបោកបញ្ឆោតរបស់មេខ្យល់ ដែលសន្យារៀបចំឲ្យពួកនាងរៀបអាពាហ៍ពិពាហ៍ជាមួយនឹងបុរសអ្នកមានជនជាតិចិន។ ពួកនាងបានទទួលយកការសន្យាដែលពួកនាងយល់ថានឹងទទួលបានប្រាក់កម្រៃដោយសារតែចង់ជួយទ្រទ្រង់ជីវភាពគ្រួសារ។ តាមពិតទៅការលក់កូនក្រមុំគឺជាអាជីវកម្មដែលមេខ្យល់ជាអ្នកទទួលផលប្រយោជន៍ ចំណែកឯក្រុមគ្រួសាររបស់ជនរងគ្រោះនៅទីបញ្ចប់ទទួលបានប្រាក់តែប៉ុណ្ណានដុល្លារតែប៉ុណ្ណោះ បន្ទាប់ពីលះបង់កូនស្រីរបស់ខ្លួនដោយឥតប្រយោជន៍ និងមិនយុត្តិធម៌។ រឹតតែអាក្រក់ជាងនេះទៅទៀត ក្រុមគ្រួសារជាច្រើនបែរជាជំពាក់បំណុលគេរឹតតែធ្ងន់ ដោយសារតែត្រូវទិញសំបុត្រយន្តហោះឲ្យកូនស្រីបានវិលត្រលប់មកប្រទេសកំណើតវិញ។

ជនរងគ្រោះវ័យក្មេងខ្លះ ព្យាយាមរត់គេច នៅពេលដែលពួកគេដឹងខ្លួនថាត្រូវមេខ្យល់ចិត្តអាក្រក់បោកបញ្ឆោត។ ទោះបីជាយ៉ាងនេះក្តី ពួកគេជាញឹកញាប់ត្រូវប្រឈមនឹងភាពអាម៉ាស់ពីសំណាក់មហាជននៅពេលដែលពួកគេបានវិលត្រលប់មកវិញ ដែលមានមហាជនជាច្រើនមើលមកពួកគេជា“ស្ត្រីអាក្រក់” ដោយសារពួកគេមិនទទួលស្គាល់ពីការប្រមាថមើលងាយ និងការធ្វើទារុណកម្ម។ វាជាការយល់ឃើញទូទៅមិនថានៅប្រទេសចិន និងប្រទេសកម្ពុជា ដែលស្ត្រីត្រូវតែចេះស្តាប់បង្គាប់ និងគោរពស្វាមីរបស់ពួកគេ។ នៅពេលដែលជ្រើសរើសកូនក្រមុំ កូនក្រមុំកាន់តែក្មេងកាន់តែអៀន និងមានចំណេះដឹងតិច គឺកាន់តែល្អ។ គុណសម្បត្តិខ្លះដូចជា កម្លាំង ជំនឿចិត្តភាពឆ្លាតវៃ និងភាពក្លាហាន គឺនៅតែត្រូវបានគេចាត់ទុកថាជាអាកប្បកិរិយាមិនត្រឹមត្រូវសម្រាប់ស្ត្រី។ កូនក្រមុំ ដែលសម្រេចចិត្តតបតប្រឆាំងនឹងការរំលោភបំពានក្នុងអាពាហ៍ពិពាហ៍ តែងតែត្រូវបានថ្កោលទោសដោយសង្គម។

យ៉ាងណាក៏ដោយ យុទ្ធសាស្ត្រមួយសម្រាប់សង្គមក្នុងការអភិវឌ្ឍទៅមុខ គឺការផ្តល់តួនាទីសំខាន់ឲ្យស្ត្រី។ អ្វីៗគួរតែចាប់ផ្តើមជាមួយនឹងការផ្លាស់ប្តូរចិត្តគំនិត ដែលក្នុងពេលបច្ចុប្បន្នគឺជាឬសគល់នៃអំពើហិង្សាលើស្ត្រី។ ប្រជាជនកម្ពុជាគ្រប់រូប ទាំងបុរស និងស្ត្រី ត្រូវតែសហការគ្នាយ៉ាងជិតស្និត ដើម្បីគាំទ្រស្ត្រីក្នុងការបង្ហាញពីខ្លួនពួកគេ និងប្រឆាំងតបនឹងការរស់នៅក្នុងស្ថានភាពរំលោភបំពាន។

ស្ត្រីកម្ពុជាដែលក្លាហានជាច្រើនទៀតនឹងវិលត្រលប់ចេញពីប្រទេសចិន និងប្រទេសដទៃផ្សេងទៀត។ ចំណែកឯស្ត្រីដទៃផ្សេងទៀតនឹងជម្រុញសេចក្តីក្លាហានរបស់ពួកគេក្នុងការចាកចេញពីការរំលោភបំពានពីបុរសជាស្វាមីនៅក្នុងប្រទេសកម្ពុជា។ ពួកគេទាំងអស់គ្នាសាកសមនឹងទទួលការគោរព និងការគាំទ្រយ៉ាងពេញលេញពីពួកយើង។

## លេខទូរស័ព្ទសារជាសំឡេង ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ០៩៥ ៩៧៥ ៨០៤

## ប្រសិនបើអ្នកបានជួបប្រទះ ឬធ្លាក់ក្នុងអំពើជួញដូរមនុស្ស អ្នកអាចស្វែងរកជំនួយបានតាមរយៈ លេខទំនាក់ទំនងដូចខាងក្រោម

### ក្នុងប្រទេសកម្ពុជា

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន
០២៣ ៩៩ ៧៩ ១៩
ឬ ១២៨៨ (ហៅចូលដោយឥតគិតថ្លៃ)

**ការិយាល័យនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៅតាមបណ្តាខេត្ត ក្រុង**

| | |
|---|---|
| ក្រុងភ្នំពេញ | ០១៧ ២៧៦ ២២២ |
| ខេត្តសៀមរាប | ០១៧ ២៥៨ ២២២ |
| ខេត្តបាត់ដំបង | ០១៧ ២៣៦ ២២២ |
| ខេត្តកំពង់ធំ | ០១៧ ២៥៤ ២២២ |
| ខេត្តបន្ទាយមានជ័យ | ០១៧ ២៦០ ២២២ |
| ខេត្តកំពង់ឆ្នាំង | ០១៧ ៣២៦ ២២២ |
| ក្រុងព្រះសីហនុ | ០១៧ ២៥៩ ២២២ |

### លេខទំនាក់ទំនងអង្គការនៅក្នុងប្រទេសកម្ពុជា

អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC)
០៩៨ ៣៦០ ០៤៩ (ប៉ោយប៉ែត)
០៨៨ ៦៩៥ ៤១៧៨ (សៀមរាប)

អង្គការខារ៉ាមកម្ពុជា (CARAM)
០១២ ៩៤៩ ៩១៤

អង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី (LSCW)
០៧៧ ៤៥៥ ៥១៦

អង្គការមជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ (CCPCR)
០១២ ៩១៣ ១៣៨

### លេខទំនាក់ទំនងនៅក្រៅប្រទេស

ស្ថានទូតកម្ពុជា នៅប្រទេសថៃ
+៦៦ ២៩ ៥៧៥ ៨៥១

អង្គការសម្ព័ន្ធសកលប្រឆាំងអំពើជួញដូរស្ត្រី នៅប្រទេសថៃ (GAATW)
+៦៦ ២៨ ៦៤១ ៤២៧

អង្គការ LPN នៅប្រទេសថៃ
+៦៦ ៣៤ ៤៣៤ ២៦៧

ស្ថានទូតកម្ពុជា នៅប្រទេសម៉ាឡេស៊ី
+៦០ ៣៤ ២៥៧ ១១៥០
+៦០ ៣៤ ២៥៧ ៣៧១១

អង្គការទីណាហ្គានីតា នៅប្រទេសម៉ាឡេស៊ី
+៦០ ៣៧ ៧៧០ ៣៦៩១

ក្រសួងការងារ នៅប្រទេសសិង្ហបុរី (MOM)
+៦៥ ៦៤ ៣៨៥ ១២២ (សម្រាប់សំណួរទូទៅ)
+៦៥ ៦៥ ៣៨៦ ៩៣០ (សំណួរទាក់ទងនឹងគុណភាពសេវាកម្ម)

ភ្នាក់ងារពឹងពាក់សម្រាប់អ្នកបម្រើដែលស្នាក់នៅបណ្តោះអាសន្ន នៅប្រទេសសិង្ហបុរី (TWC2)
+៦៥ ៦២ ៤៧៧ ០០១

អង្គការមនុស្សធម៌សម្រាប់សេដ្ឋកិច្ចនៃការធ្វើទេសន្តប្រវេសន៍ នៅប្រទេសសិង្ហបុរី (HOME)
បណ្តាញជំនួយ២៤ម៉ោងសម្រាប់ស្ត្រី និងបុរស បំរើការងារតាមផ្ទះ:
+៦៥ ៦៣ ៤១៥ ៥២៥ (សម្រាប់ស្ត្រី)
+៦៥ ៦៣ ៤១៥ ៥៣៥ (សម្រាប់បុរស)

អង្គការវីនរ៉ក់អន្តរជាតិ ជាអង្គការមិនរកផលចំណេញ ដែលធ្វើការជាមួយប្រជាជនក្នុងសហរដ្ឋអាមេរិក និង នៅទូទាំងពិភពលោក ដើម្បីជួយដល់ជនក្រីក្រ បង្កើនឱកាសរកប្រាក់ចំណូល និងថែរក្សាធនធានធម្មជាតិអោយបានគង់វង្ស។

WINROCK INTERNATIONAL
Putting Ideas to Work

ការិយាល័យអង្គការវីនរ៉ក់នៅប្រទេសកម្ពុជា
មជ្ឈមណ្ឌលភ្នំពេញ អគារ អែហ្វ បន្ទប់លេខ ៧៨៧ មហាវិថី សុធារស រាជធានីភ្នំពេញ ទូរស័ព្ទ: +៨៥៥-២៣ ២១២ ៣៣៤/៦ ទូរសារ: +៨៥៥-២៣ ២១២ ៣៣៥
សារអេឡិចត្រូនិច: camille.dumont@winrock.org
គេហទំព័រ: www.facebook.com/CTIP2